# មគ្គុទេសក៍ព័ត៌មានស្តីពីការជួញដូរ និងកេងប្រវ័ញ្ចមនុស្ស



## តើការជួញដូរមនុស្សជាអ្វី ?

ការជួញដូរមនុស្សកើតឡើងនៅពេលមនុស្សម្នាក់បញ្ឆោ ឬគ្រប់គ្រងមនុស្សម្នាក់ទៀត ដើម្បីផ្តល់កម្លាំងពលកម្ម ឬការរួមភេទដើម្បីផលប្រយោជន៍របស់មនុស្សម្នាក់ទៀត។ តាមច្បាប់នៃរដ្ឋ Minnesota ការជួញដូរមនុស្សអាចកើតឡើងតាមគ្រប់រូបភាព។ តាមច្បាប់សហព័ន្ធ ការជួញដូរតម្រូវឱ្យប្រើកម្លាំង ការក្លែងបន្លំ ឬការបង្ខិតបង្ខំ ដើម្បីបង្ខំជនរងគ្រោះឱ្យធ្វើការ ឬផ្តល់សេវាកម្មលក់ផ្លូវភេទ។ ជនរងគ្រោះនៃការជួញដូរមនុស្សមិនអាចចាកចេញពីស្ថានភាពរបស់ពួកគេដោយសារមូលហេតុផ្សេងៗគ្នា។

**ដើម្បីគ្រប់គ្រងជនរងគ្រោះរបស់ពួកគេ អ្នកជួញដូរអាចប្រើវិធីជាច្រើនរួមទាំងប៉ុន្តែមិនកំណត់ត្រឹមតែះ**

- ការបំភិតបំភ័យ
- ការបង្ខិតបង្ខំ និងការគំរាមកំហែង
- ការរំលោភបំពាន (ផ្លូវចិត្ត ផ្លូវកាយ ផ្លូវភេទ)
- ការបង្ខាំងទុកដាច់តែឯង
- ការបដិសេធ ការស្តីបន្ទោស និងការបន្ធូរបន្ថយ
- ឯកសិទ្ធិ និងឧត្តមភាព
- ការរំលោភបំពានផ្នែកសេដ្ឋកិច្ច
- ការដឹងពីកាតព្វកិច្ចចំពោះគ្រួសារជនរងគ្រោះ
- ការដកហូតឯកសារ

**មិនមានសញ្ញាតែមួយគត់អាចកំណត់បានច្បាស់ពីការជួញដូរមនុស្សទេ។ ប្រការសំខាន់បំផុតនោះគឺត្រូវស្វែងរកគំរូនៃការគ្រប់គ្រងរបស់អ្នកជួញដូរលើមនុស្សម្នាក់ ឬច្រើននាក់**

## តើការកេងប្រវ័ញ្ចគឺជាអ្វី ?

ការកេងប្រវ័ញ្ចកើតឡើងនៅពេលមនុស្សម្នាក់ធ្វើបាបមនុស្សម្នាក់ទៀតដោយអយុត្តិធម៌ ដើម្បីទទួលបានអត្ថប្រយោជន៍ពីការងាររបស់ពួកគេ។ មានអំណាចមិនស្មើគ្នារវាងអ្នកកេងប្រវ័ញ្ច និងជនរងគ្រោះ ជាមួយអ្នកកេងប្រវ័ញ្ចដែលកាន់អំណាច។ ការកេងប្រវ័ញ្ចអាចត្រូវបានមើលឃើញថាជាចំណុចកណ្តាលរវាងសេរីភាពទាំងស្រុង និងការជួញដូរមនុស្ស។ ស្ថានភាពទាំងនេះអាចត្រួតលើគ្នា ហើយបុគ្គលម្នាក់ៗអាចទទួលបទពិសោធន៍នៃកន្លែងផ្សេងៗគ្នារវាងសេរីភាព និងការជួញដូរនៅពេលខុសគ្នា។

ការកេងប្រវ័ញ្ចពាណិជ្ជកម្មផ្លូវភេទកើតឡើងនៅពេលដែលជនណាម្នាក់ផ្តល់ឲ្យនូវការរួមភេទជាថ្នូរនឹងយករបស់ដែលមានតម្លៃ ឬការសន្យាឲ្យរបស់ដែលមានតម្លៃដូចជាលុយកាក់ ថ្នាំសង្កូវ ម្ហូបអាហារ ទីជម្រក ថ្លៃឈ្នួល ឬឋានៈខ្ពង់ខ្ពស់នៅក្នុងក្រុមក្មេងទំនើង ឬក្រុមមនុស្ស។ ការកេងប្រវ័ញ្ចកម្លាំងពលកម្មធ្វើឲ្យកម្មករអនុវត្តការងារដោយអយុត្តិធម៌ ហើយអាចរាប់បញ្ចូលការបដិសេធបើកប្រាក់ខែ ឬបើកឈ្នួលមិនគ្រប់សម្រាប់ថ្លៃពលកម្ម ឬការលួចប្រាក់ឈ្នួល (ដកហូតប្រាក់ឈ្នួលដែលបានសន្យាដោយស្របច្បាប់ ឬតាមកិច្ចសន្យារួមទាំងការថែមម៉ោង)។

## តើអ្នកណាជាអ្នកជួញដូរ និងអ្នកទិញ ?

មនុស្សគ្រប់វ័យ ជាតិសាសន៍ ពូជសាសន៍ ឬភេទអាចជាអ្នកជួញដូរ។ អ្នកជួញដូរអាចជាសមាជិកគ្រួសារ ឬជាមិត្តជិតស្និទ្ធ ឬក៏អាចជាមិត្តប្រុស មិត្តស្រី ឬក៏ជាសហព័ទ្ធ។

ដូចអ្នកជួញដូរដែរ អ្នកទិញអាចជាជនគ្រប់វ័យ ជាតិសាសន៍ ពូជសាសន៍ ឬភេទ។ ពួកគេមកពីសហគមន៍តំបន់ទីក្រុង ជនបទ និងជាយក្រុង។ អ្នកទិញប្រើបណ្តាញអ៊ីនធឺណិត ការស្នើសុំដោយផ្ទាល់ និងពាក្យសម្ដីផ្ទាល់មាត់ដើម្បីទិញការរួមភេទ។

## តើអ្នកណាជាជនរងគ្រោះ ?

ជនណាម្នាក់អាចក្លាយជាជនរងគ្រោះនៃការជួញដូរមនុស្ស។ ជនរងគ្រោះ/អ្នករស់រានមានជីវិតមកពីគ្រប់មជ្ឈដ្ឋាន ពូជសាសន៍ ភេទ ទំនោរផ្លូវភេទ ស្ថានភាពសញ្ជាតិ និងស្ថានភាពសេដ្ឋកិច្ច។

អ្នកជួញដូរកំណត់គោលដៅលើបុគ្គលដោយហេតុផលណាមួយ ដែលងាយទទួលរងគ្រោះពីឧបាយកល និងការគ្រប់គ្រងរបស់អ្នកជួញដូរ។ ស្ថានភាពសង្គមរបស់សហគមន៍ដូចជាអត្រាគ្មានការងារធ្វើខ្ពស់ ឬកង្វះធនធានអាចបង្កភាពកាន់តែងាយស្រួលដល់អ្នកជួញដូរផ្ដោតគោលដៅលើជនរងគ្រោះ។ លក្ខខណ្ឌដែលបង្កើនហានិភ័យនៃការជួញដូររួមមាន៖

- ភាពក្រីក្រ
- ភាពអត់ការងារធ្វើ
- ទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ
- អាយុ - កុមារ យុវជន មនុស្សចាស់
- ស្ថានភាពអន្តោប្រវេសន៍
- ជនជាតិភាគតិច
- ប្រវត្តិនៃការរំលោភបំពាន
- ភាពពឹងលើសារធាតុគីមី
- ស្ថានភាពពិការភាព
- ភាពគ្មានផ្ទះសម្បែង

## តើខ្ញុំគួរនិយាយអំពីការជួញដូរមនុស្សយ៉ាងដូចម្ដេច ?

ពាក្យដែលយើងប្រើមានឥទ្ធិពលលើរបៀបដែលយើងមើលស្ថានភាព និងអ្នកដទៃ។ វាចាំបាច់ក្នុងការប្រើពាក្យដែលបន្ថយការមាក់ងាយ និងអនុញ្ញាតឱ្យមនុស្សមានអារម្មណ៍ទទួលយកបាន ដូច្នេះពួកគេអាចមករកជំនួយដោយគ្មានការខ្មាស់អៀន។ ប្រើពាក្យដែលងាយយល់ និងសមរម្យដូចជាការធ្វើអាជីវកម្មផ្លូវភេទ ជនរងគ្រោះនៃការជួញដូរមនុស្ស អ្នករស់រានមានជីវិត ឬអ្នកដែលបានទទួលរងការកេងប្រវ័ញ្ច ឬការជួញដូរ។

## តើខ្ញុំត្រូវធ្វើដូចម្ដេច ប្រសិនបើខ្ញុំសង្ស័យករណីជួញដូរមនុស្ស ?

- សូមទាក់ទង Safe Harbor Regional Navigator (http://www.health.state.mn.us/communities/safeharbor/response/navigators.html) ឬទាក់ទងមកលេខទូរស័ព្ទទាន់ហេតុការណ៍តាមពេញមួយថ្ងៃ (Day One Hotline ) លេខ 1-866-223-1111 ដើម្បីស្វែងយល់បន្ថែមអំពីសេវាកម្មដែលមាន នៅក្នុងតំបន់របស់អ្នក។
- រាយការណ៍ពីករណីសង្ស័យពីបទជួញដូរទៅកាន់ទម្រង់គន្លឹះ (Tip Form) នៃការិយាល័យចំណាប់ជនឧក្រិដ្ឋ (BCA) ឬទូរស័ព្ទទៅ BCA តាមលេខ 1-877-996-6222 ឬអ៊ីមែល៖ bca.tips@state.mn.us ។
- ទូរស័ព្ទទៅ 911 ប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ស្ថិតនៅក្នុងភាពគ្រោះថ្នាក់ភ្លាមៗ។

## ធនធាន

- Minnesota Safe Harbor (https://www.health.state.mn.us/communities/safeharbor/index.html)
- លេខទូរស័ព្ទទាន់ហេតុការណ៍ពេញមួយថ្ងៃ (Minnesota Day One Crisis Hotline) - 866-223-1111

SAFE HARBOR

DEPARTMENT OF HEALTH

មគ្គុទេសក៍នេះត្រូវបានផលិតដោយក្រសួងសុខាភិបាលនៃរដ្ឋ Minnesota ដោយមានលេខ 2016-MU-MU-K153 ដែលផ្ដល់ដោយការិយាល័យដើម្បីជនរងគ្រោះនៃឧក្រិដ្ឋកម្ម កម្មវិធីការិយាល័យយុត្តិធម៌នៃក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក។ មតិយោបល់ ឬអនុសាសន៍ដែលបានបង្ហាញនៅក្នុងសៀវភៅមគ្គុទេសក៍នេះគឺជាកម្មសិទ្ធិរបស់អ្នកចូលរួមវិភាគទាន ហើយមិនតំណាងឱ្យគោលជំហរបស់ការិយាល័យ ឬគោលនយោបាយរបស់ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិកទេ។

បានកែសម្រួលចុងក្រោយ 3/2020